# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ៣០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតនិងចាត់តាំងក្រុមអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ
## រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិងចាត់តាំងក្រុមអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | អេង ទួច | រដ្ឋលេខាធិការនិងជានាយកខុទ្ទកាល័យ | ប្រធាន |
| ២- | ឯកឧត្តម | ទិត សុធា | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម | ហ៊ុយ វណ្ណៈ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤- | លោកជំទាវ | អ៊ុង ច័ន្ទសោភា | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥- | ឯកឧត្តម | ម៉ក់ វេនីតា | អនុរដ្ឋលេខាធិការ | សមាជិក |

**ប្រការ២.-**

ក្រុមអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គ្រប់គ្រង ធ្វើនិយ័តកម្មលើការផ្សព្វផ្សាយរាល់ព័ត៌មានផ្លូវការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំសេចក្តីបំភ្លឺ សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ និងការផ្សព្វផ្សាយផ្សេងទៀតអំពីព័ត៌មានរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- ទំនាក់ទំនងនិងឆ្លើយតបជាផ្លូវការជាមួយសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ
- សហការជាមួយអង្គភាពនានាចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីប្រមូលព័ត៌មាន តាមដាន អង្កេត និងវិភាគនូវរាល់ព័ត៌មាន និងឯកសារពាក់ព័ន្ធ សម្រាប់ធ្វើការឆ្លើយបំភ្លឺជូនសាធារណជន និងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ
- ស្រាយបំភ្លឺចំណោទបញ្ហានានាដែលកើតមានឡើងក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំសន្និសីទសារព័ត៌មាននានាជូនថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី
- ស្រាវជ្រាវនិងប្រមូលចងក្រងរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងទីស្តីការគណៈរដ្ឋមន្ត្រី
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ ប្រធានគ្រប់អង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ